

# ឧបសម្ព័ន្ធ ក
# តារាងអភិវឌ្ឍរបស់កុមារ

## របៀបប្រើតារាងអភិវឌ្ឍកុមារ

កុមារអភិវឌ្ឍនៅក្នុងផ្នែកចំបងមួយចំនួន :- **កាយសម្បទា** ( រាងកាយ) **គំនិតបញ្ញា** ( ខួរក្បាល) **ការប្រាស្រ័យទាក់ទង** ( កាយវិការ ឬ និយាយ) និង**សង្គម** ( ផ្សារភ្ជាប់ខ្លួនទៅមនុស្សឯទៀត) ។ បំណិនមួយចំនួនដែលកុមាររៀនរួមបញ្ចូលផ្នែកទាំងអស់នេះ ។ ឧទាហរណ៍ នៅពេលកុមារលើកដៃសុំឱ្យគេពខ្លួន ពេលនោះក្មេងកំពុងប្រើ :-

- បំណិនកាយសម្បទា - កុមារលើកដៃឡើងលើ
- បំណិនគំនិតបញ្ញា - កុមារស្គាល់អ្នក
- ការប្រាស្រ័យទាក់ទង - កុមារប្រាប់អ្នកនូវអ្វីដែលគេចង់បាន
- បំណិនសង្គម -កុមាររីករាយនឹងការដែលអ្នកពគេ



តារាងនៅលើទំព័រ 178 និង 183 បង្ហាញបំណិនខ្លះដែលកុមាររៀន និងពេលដែលកុមារភាគច្រើនរៀនបំណិនទាំងនោះ ។ អ្នកអាចប្រើតារាងដើម្បីទទួលបានព័ត៌មានទូទៅ អំពីរបៀបដែលកុមារអភិវឌ្ឍ និងដើម្បីជួយអ្នកសំរេចចិត្តយកបំណិនអ្វីខ្លះដែលកូនរបស់អ្នកត្រូវការរៀន ។




**តារាងបង្ហាញរបៀបដែលបំណិនកាយសម្បទារបស់កុមារប្រែប្រួល នៅពេលកុមារលូតលាស់**

### ➢ របៀបជួយអ្នកឱ្យសំរេចចិត្តជ្រើសរើសបំណិនអ្វីខ្លះដែលកូនរបស់អ្នកត្រូវការរៀន

ចូររកតារាងសំរាប់ក្រុមអាយុជិតស្មើនឹងវ័យរបស់កូនអ្នក ។ ចូរគូសរង្វង់ត្រង់បំណិនដែលកូនចេះហើយលើតារាង ។ អ្នកអាចរកឃើញថា កូនរបស់អ្នកមិនទាន់ចេះបំណិនមួយចំនួនដែលកុមារឯទៀតមានវ័យស្រករនឹងគេចេះរួចហើយ ។ ការដឹងបែបនេះអាចជួយអ្នកឱ្យសំរេចចិត្តថា តើសកម្មភាពណាខ្លះដែលអ្នកត្រូវអនុវត្តជាមួយកូន ។

**បើសិនជាកូនរបស់អ្នកលូតលាស់យឺតជាងកុមារឯទៀត**

ចូរប្រើសៀវភៅនេះជាគំរូនាំមុខ ។ ជំពូកនីមួយៗក្នុងប្រអប់មានពន្យល់យ៉ាងច្រើនអំពីបំណិនទាំងនេះ និងលំដាប់លំដោយនៃបំណិនដែលត្រូវការរៀនសូត្រ ។ **វាគឺជាការសំខាន់ដើម្បីធ្វើការលើបំណិនដែលកូនអ្នកត្រូវការរៀនបន្ទាប់ទៀត មិនមែនបំណិនដែលក្មេងដទៃមានអាយុស្រករកូនអ្នកកំពុងរៀននោះទេ ។** ការព្យាយាមបង្រៀនបំណិន មុនពេលដែលកុមារត្រៀមស្រេចបាច់ដើម្បីរៀននោះ វាបណ្តាលឱ្យមានការតឹងតែងក្នុងចិត្តទាំងកូន និង អ្នក ។




នៅក្នុងតារាងខាងលើ ម្តាយរបស់ក្មេងម្នាក់បានគូសរង្វង់ជុំវិញបំណិននានាដែលកូនស្រីអាយុ 20 ខែរបស់គាត់អាចធ្វើបាន ។ កូនស្រីគាត់ត្រូវការសកម្មភាពជួយផ្នែកបំណិនប្រាស្រ័យទាក់ទង និងផ្នែកគំនិតបញ្ញាឱ្យបានកើនឡើង ។ ដំបូងចូរមើលក្នុងជំពូកដែលផ្តោតលើបំណិននានាដែលអ្នកចង់បង្រៀនកូន ហើយអ្នកនឹងរកឃើញព័ត៌មានដែលមានប្រយោជន៍នៅក្នុងជំពូកដទៃទៀតផងដែរ ។

**ជំពូក** →

តំបន់នៃការអភិវឌ្ឍ ↓

| | សកម្មភាពសំរាប់ទារកតូច 5 | ការប្រាស្រ័យទាក់ទង 6 | បំណិនការគិត 7 | ការបង្រៀនអំពីសកម្មភាពប្រចាំថ្ងៃ 8 | ការបំលាស់ទីតាំង 10 | ការជួយកូនអ្នកឲ្យដឹងថានៅកន្លែងណា 11 | ការក្លាយជាចំណែកនៃសហគមន៍ 13 | ត្រៀមកុមារសំរាប់ចូលសាលារៀន 14 |
|---|---|---|---|---|---|---|---|---|
| កាយសម្បទា | ● | | | ● | ● | ● | ● | |
| គំនិតបញ្ញា | ● | | ● | | | ● | | ● |
| សង្គម | ● | | | ● | | | ● | ● |
| ប្រាស្រ័យទាក់ទង | ● | ● | | | | | ● | |

ចំណែកនីមួយៗនៃរង្វង់នេះ បង្ហាញផ្នែកខុសៗគ្នានៃការអភិវឌ្ឍ ។ រូបភាព និង ពាក្យ គឺជាឧទាហរណ៍នៃបំណិន ដែលទារកជាច្រើនតែងចេះនៅពេលពួកគេ**អាយុ 3 ខែ** ។




ទារកដែលមិនអាចអនុវត្តបំណិនពីរនៅក្នុងផ្នែកណាមួយនៃរង្វង់មូល នឹងទទួលបានផលប្រយោជន៍ពីសកម្មភាពជួយទារកឱ្យអភិវឌ្ឍនៅក្នុងផ្នែកនោះ ប៉ុន្តែរូបភាពគឺគ្រាន់តែជា**ឧទាហរណ៍**នៃបំណិននានាប៉ុណ្ណោះ ។ ឧទាហរណ៍នៅក្នុងផ្នែក**ការប្រាស្រ័យទាក់ទង**"នៃរង្វង់មូល : អ្នកមិនចាំបាច់ផ្លុំខ្លុយដូចក្នុងរូបភាពនោះទេ! សំណួរដែលអ្នកត្រូវសួរខ្លួនឯងគឺ ថាតើទារករបស់អ្នកមានប្រតិកម្មតបភ្លាមៗទៅកាន់សម្លេងដែរឬទេ?

**ចូរចងចាំក្នុងគំនិតថា ទារកនឹងរៀនបានល្អបំផុតដោយការធ្វើសកម្មភាពទាំងឡាយណាដែលទារកដទៃនៅក្នុងសហគមន៍របស់អ្នក មានវ័យស្មើនឹងកូនរបស់អ្នកធ្វើសកម្មភាពទាំងនោះ ។**

ចំណែកនីមួយៗនៃរង្វង់នេះ បង្ហាញផ្នែកខុសៗគ្នានៃការអភិវឌ្ឍ ។ រូបភាព និង ពាក្យ គឺជាឧទាហរណ៍នៃបំណិន ដែលទារកជាច្រើនតែងចេះនៅពេលពួកគេ**អាយុ 6 ខែ** ។




ទារកដែលមិនអាចអនុវត្តបំណិនពីរ នៅក្នុងចំណែកណាមួយនៃរង្វង់មូលនឹងទទួលបានផលប្រយោជន៍ពីសកម្មភាពជួយទារកឱ្យអភិវឌ្ឍនៅក្នុងផ្នែកនោះ ប៉ុន្តែរូបភាពគឺគ្រាន់តែជា**ឧទាហរណ៍**នៃបំណិននានាប៉ុណ្ណោះ ។ ឧទាហរណ៍ នៅក្នុងចំណែក **"កាយសម្បទា"** នៃរង្វង់មូល : ទារករបស់អ្នកមិនចាំបាច់លេងចង្រ្កង់ដូចក្នុងរូបភាពនោះទេ! សំណួរដែលអ្នកត្រូវសួរខ្លួនឯង គឺថាតើទារករបស់អ្នកចេះបម្រះ និងទធាក់ដៃរឬទេ?

**ចូរចងចាំក្នុងគំនិតថា ទារកនឹងរៀនបានល្អបំផុតដោយការធ្វើសកម្មភាពទាំងឡាយណាដែលទារកដទៃទៀតនៅក្នុងសហគមន៍របស់អ្នក មានវ័យស្មើនឹងកូនរបស់អ្នកធ្វើសកម្មភាពទាំងនោះ ។**

ចំណែកនីមួយៗនៃរង្វង់នេះ បង្ហាញផ្នែកខុសៗគ្នានៃការអភិវឌ្ឍ ។ រូបភាព និង ពាក្យ គឺជាឧទាហរណ៍នៃបំណិន ដែលទារកជាច្រើនតែងចេះនៅពេលពួកគេ**អាយុ 12 ខែ** ។




ទារកដែលមិនអាចធ្វើបំណិនពីរ នៅក្នុងចំណែកណាមួយនៃរង្វង់មូលនឹងទទួលបានផលប្រយោជន៍ពីសកម្មភាពជួយទារកឱ្យអភិវឌ្ឍនៅក្នុងផ្នែកនោះ ប៉ុន្តែរូបភាពគឺគ្រាន់តែជា**ឧទាហរណ៍**នៃបំណិននានាប៉ុណ្ណោះ ។ ឧទាហរណ៍ នៅក្នុងចំណែក "**សង្គម**" នៃរង្វង់មូល : អ្នកមិនចាំបាច់លេងបិទពួនដូចក្នុងរូបភាពនោះទេ! សំណួរដែលអ្នកត្រូវសួរខ្លួនឯង គឺថាតើទារករបស់អ្នករីករាយលេងល្បែងកំសាន្តនៃសង្គមដែរឬទេ?

**ចូរចងចាំក្នុងគំនិតថា ទារកនឹងរៀនបានល្អបំផុតដោយការធ្វើសកម្មភាពទាំងឡាយណាដែលទារកដទៃនៅក្នុងសហគមន៍របស់អ្នក មានវ័យស្មើនឹងកូនរបស់អ្នកធ្វើសកម្មភាពទាំងនោះ ។**

ចំណែកនីមួយៗនៃរង្វង់នេះ បង្ហាញផ្នែកខុសៗគ្នានៃការអភិវឌ្ឍ ។ រូបភាព និង ពាក្យ គឺជាឧទាហរណ៍នៃបំណិន ដែលទារកជាច្រើនតែងចេះនៅពេលពួកគេ**អាយុ 2 ឆ្នាំ** ។




កុមារដែលមិនអាចធ្វើបំណិនពីរ នៅក្នុងចំណែកណាមួយនៃរង្វង់មូលនឹងទទួលបានផលប្រយោជន៍ពីសកម្មភាពជួយកុមារឱ្យអភិវឌ្ឍនៅក្នុងផ្នែកនោះ ប៉ុន្តែរូបភាពគឺគ្រាន់តែជា**ឧទាហរណ៍**នៃបំណិននានាប៉ុណ្ណោះ ។ ឧទាហរណ៍ នៅក្នុងចំណែក **"គំនិតបញ្ញា"**នៃរង្វង់មូល : កូនរបស់អ្នកមិនចាំបាច់វាយស្គរដូចក្នុងរូបភាពនោះទេ! សំណួរដែលអ្នកត្រូវសួរខ្លួនឯងគឺ ថាតើកូនអ្នកចេះប្រើវត្ថុពីរដែលទាក់ទងគ្នាទៅវិញទៅមកដែរឬទេ?

**ចូរចងចាំក្នុងគំនិតថា ទារកនឹងរៀនបានល្អបំផុតដោយការធ្វើសកម្មភាពទាំងឡាយណាដែលទារកដទៃនៅក្នុងសហគមន៍របស់អ្នក មានវ័យស្មើនឹងកូនរបស់អ្នកធ្វើសកម្មភាពទាំងនោះ ។**

ចំណែកនីមួយៗនៃរង្វង់នេះ បង្ហាញផ្នែកខុសៗគ្នានៃការអភិវឌ្ឍ ។ រូបភាព និង ពាក្យ គឺជាឧទាហរណ៍នៃបំណិន ដែលទារកជាច្រើនតែងចេះនៅពេលពួកគេ**អាយុ 3 ឆ្នាំ** ។




កុមារដែលមិនអាចធ្វើបំណិនពីរនៅក្នុងចំណែកណាមួយនៃរង្វង់មូល នឹងទទួលបានផលប្រយោជន៍ពីសកម្មភាពជួយកុមារឱ្យអភិវឌ្ឍនៅក្នុងផ្នែកនោះ ប៉ុន្តែរូបភាពគ្រាន់តែជា**ឧទាហរណ៍**នៃបំណិននានាប៉ុណ្ណោះ ។ ឧទាហរណ៍ នៅក្នុងចំណែក "**សង្គម**" នៃរង្វង់មូល : កូនរបស់អ្នកមិនចាំបាច់ធ្វើសកម្មភាពជូតផ្ទះដូចក្នុងរូបភាពនោះទេ! សំណួរដែលអ្នកត្រូវសួរខ្លួនឯង គឺថាតើកូនអ្នករីករាយនឹងជួយធ្វើកិច្ចការផ្ទះជាមួយគ្រួសារដែរឬទេ?

**ចូរចងចាំក្នុងគំនិតថា ទារកនឹងរៀនបានល្អបំផុតដោយការធ្វើសកម្មភាពទាំងឡាយណាដែលទារកដទៃនៅក្នុងសហគមន៍របស់អ្នក មានវ័យស្មើនឹងកូនរបស់អ្នកធ្វើសកម្មភាពទាំងនោះ ។**

ចំណែកនីមួយៗនៃរង្វង់នេះ បង្ហាញផ្នែកខុសៗគ្នានៃការអភិវឌ្ឍ ។ រូបភាព និង ពាក្យ គឺជាឧទាហរណ៍នៃបំណិន ដែលទារកជាច្រើនតែងចេះនៅពេលពួកគេ**អាយុ 5 ឆ្នាំ** ។




កុមារដែលមិនអាចធ្វើបំណិនពីរនៅក្នុងចំណែកណាមួយនៃរង្វង់មូល នឹងទទួលបានផលប្រយោជន៍ពីសកម្មភាពជួយកុមារឱ្យអភិវឌ្ឍនៅក្នុងផ្នែកនោះ ប៉ុន្តែរូបភាពគឺគ្រាន់តែជា**ឧទាហរណ៍**នៃបំណិននានាប៉ុណ្ណោះ ។ ឧទាហរណ៍ នៅក្នុងចំណែក"**សង្គម**"នៃរង្វង់មូល : កូនរបស់អ្នកមិនចាំបាច់ធ្វើសកម្មភាពស្ដាប់គ្រូបង្រៀនដូចក្នុងរូបភាពនោះទេ! សំណួរដែលអ្នកត្រូវសួរខ្លួនឯង គឺថាតើកូនរបស់អ្នកយល់ពីវិន័យដូចកុមារដទៃដែរឬទេ?

**ចូរចងចាំក្នុងគំនិតថា ទារកនឹងរៀនបានល្អបំផុតដោយការធ្វើសកម្មភាពទាំងឡាយណាដែលទារកដទៃនៅក្នុងសហគមន៍របស់អ្នក មានវ័យស្មើនឹងកូនរបស់អ្នកធ្វើសកម្មភាពទាំងនោះ ។**